ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ០០៧/២៦ ររ.បក

# របាយការណ៍
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែវិច្ឆិកា និងទិសដៅខែធ្នូ ឆ្នាំ២០២៥

## I. ស្ថានភាពទូទៅ

ពិភពលោក កំពុងតែប្រឈមដោះស្រាយវិបត្តិសេដ្ឋកិច្ចជាសកល ផលប៉ះពាល់នៃគ្រោះធម្មជាតិ ដែលកើតឡើងដោយបម្រែបម្រួលអាកាសធាតុ និងជម្លោះប្រដាប់អាវុធដ៏រ៉ាំរ៉ៃ និងសង្គ្រាមបង្ហូរឈាម វិបត្តិនយោបាយបានកើតឡើងជាបន្តបន្ទាប់ និងរាលដាលពីតំបន់មួយទៅតំបន់មួយ ចរន្តគាំពារនិយម ភាពក្រីក្រ ជាបុព្វហេតុជំរុញឱ្យមនុស្សរាប់លាននាក់ បង្ខំចិត្តចាកចេញពីផ្ទះសម្បែង ឬទីតាំងដែលខ្លួនរស់នៅ ហើយធ្វើទេសន្តរប្រវេសន៍ដោយគ្មានការត្រៀមទុក ដែលក្លាយជាចលនាវំហូរពលករដែលគ្មានឯកសារ ខ្វះការគ្រប់គ្រង និងប្រឈមយ៉ាងខ្លាំងទៅនឹងកង្វះសុវត្ថិភាព អំពើរំលោភបំពាន ការកេងប្រវ័ញ្ចជាច្រើនរូបភាព និងអំពើជួញដូរមនុស្ស។ អំពើជួញដូរមនុស្សជារឿងស្មុគស្មាញ និងជាបញ្ហាដ៏ធំមួយនៃសង្គមមនុស្សជាតិ ក្នុងពិភពលោក ដែលមិនមែនកើតឡើងដោយមូលហេតុតែមួយនោះទេ។

ប្រព័ន្ធផ្សព្វផ្សាយដ៏សម្បូរបែប និងការផ្សព្វផ្សាយ នៃបណ្តាញសារព័ត៌មាននានាមួយចំនួន បានលាយឡំទាំងពត៌មានពិត និងមិនពិត រួមទាំងនិន្នាការ និងភូមិសាស្ត្រនយោបាយផងនោះ បានវាយតម្លៃអំពីស្ថានភាពនៃបទល្មើសជួញដូរមនុស្សនៅកម្ពុជា។ ទន្ទឹមនឹងនោះការចោទប្រកាន់ពីបណ្តាប្រទេសមួយចំនួន ដែលមានពលរដ្ឋមកប្រព្រឹត្តបទល្មើស ឬមករងគ្រោះនៅកម្ពុជា ក៏បានធ្វើឱ្យមានការភ័ន្តច្រឡំ និងវាយតម្លៃជាអវិជ្ជមានលើស្ថានភាពសន្តិសុខនៅកម្ពុជា ដែលផ្ទុយពីឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងស្ថានភាពពិតជាក់ស្តែងនៅកម្ពុជា។

ការផ្សព្វផ្សាយអំពីឱកាសការងារ និងការជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេស ទាំងតាមប្រព័ន្ធផ្លូវការ ទាំងតាមបណ្តាញសង្គម និងមួយចំនួនធំជាការអូសទាញរបស់បណ្តាញជនល្មើស បានក្លាយជាកត្តាជំរុញ និងទាក់ទាញប្រជាពលរដ្ឋក្នុងតំបន់ និងពីបណ្តាប្រទេសនានា ក្នុងពិភពលោក ក៏ដូចជាប្រជាជនកម្ពុជា ដែលពេញវ័យការងារឱ្យចាប់អារម្មណ៍ និងសម្រេចចិត្តយ៉ាងឆាប់រហ័ស និងផុលផុសក្នុងការធ្វើចំណាកស្រុក ឬធ្វើទេសន្តរប្រវេសន៍ទៅរកការងារ ដែលមានបៀវត្សរ៍ខ្ពស់ ជាពិសេសពាក់ព័ន្ធនឹងសកម្មភាពឆបោក។ កន្លងមកចំនួនដ៏ច្រើនលើសលុបនៃប្រជាជនពេញវ័យការងារ បានធ្វើចំណាកស្រុក មានរហូតដល់ជាងមួយលាននាក់ បាននិងកំពុងនៅធ្វើការងាររហូតដល់ប្រមាណ១.៦លាននាក់ នៅក្រៅប្រទេស ដែលស្មើនឹងជិត២០ភាគរយ នៃប្រជាពលរដ្ឋវ័យ ពី១៥ឆ្នាំ ទៅ ៦០ឆ្នាំ និងអត្រាដ៏ខ្ពស់ នៃការបោះបង់ការសិក្សាក្នុងកម្រិតមធ្យមសិក្សា បានប៉ះពាល់ទៅនឹងកង្វះធនធានពលកម្ម សម្រាប់ទទួលយកការងារដែលត្រូវបានបង្កើតឡើងក្នុងស្រុក តាមរយៈការវិនិយោគលើវិស័យឧស្សាហកម្ម និងសហគ្រាសធំៗ ដែលរាជរដ្ឋាភិបាលបាននិងកំពុងទាក់ទាញការចាប់អារម្មណ៍ពីអន្តរជាតិ។

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសេនាធិការ បានចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាអាទិភាពមួយក្នុងចំណោមអាទិភាពដទៃទៀត រួមទាំងផលប៉ះពាល់នៃគ្រឿងញៀន គ្រឿងស្រវឹង គ្រោះថ្នាក់ចរាចរណ៍ និងបានដាក់ចេញនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដោយខិតខំជំរុញសកម្មភាពឥតឈប់ឈរ ដើម្បីការពារសុវត្ថិភាព និងសន្តិសុខមនុស្ស ក៏ដូចជាសន្តិសុខជាតិទាំងមូល ដើម្បីទ្រទ្រង់ដំណើរការអភិវឌ្ឍន៍គ្រប់វិស័យ នៃសង្គមជាតិ។

នៅក្នុងខែវិច្ឆិកានេះ គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងរាជធានី ខេត្ត នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់កម្រិត និងដោយមានការចូលរួមគាំទ្រ សហការពីអង្គការដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ បានធ្វើសកម្មភាពប្រតិបត្តិការយ៉ាងសកម្ម ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីឆ្លើយតបនឹងស្ថានភាពប្រែប្រួល ពិបាកប៉ាន់ស្មាននៃបទល្មើសជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀតដែលបង្កឡើងដោយឧក្រិដ្ឋជន រួមទាំងបទល្មើសឆបោកតាមប្រព័ន្ធអនឡាញផងដែរ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការបង្ការ ទប់ស្កាត់

#### ក.១. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយផ្ទាល់

ក្រុមការងារបង្ការ ទប់ស្កាត់ នៃ គ.ជ.ប.ជ ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយតាមរយៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" វេទិកាសាធារណៈ និងការបញ្ជ្រាបការផ្សព្វផ្សាយតាមកម្មវិធីផ្សេងៗ សរុបចំនួន ១៤.៨៥៥លើក មានអ្នកចូលរួមសរុបចំនួន ៩១២.៥៥១នាក់ ក្នុងនោះស្ត្រី ៤៥៥.៩៥០នាក់ (ប្រៀបធៀបនឹងខែតុលាមានចំនួន ៧៦៩.៨០៩នាក់) កើនឡើង ១៨,៥៤ ដូចមានក្នុងតារាងខាងក្រោម៖

*តារាងទិន្នន័យសរុបការផ្សអប់រំព្វផ្សាយដោយផ្ទាល់*

| ល.រ | សកម្មភាពផ្សព្វផ្សាយ | ចំនួនដង/លើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព និងវេទិកាសាធារណៈ | ១៤.៥៧៦ | ៦៩៩.០២៥ | ៣៥១.៨៧៣ |
| ២ | ការបញ្ជ្រាបតាមកម្មវិធីផ្សេងៗ | ២៧៩ | ២១៣.៥២៦ | ១០៤.០៧៧ |
| | **សរុប** | **១៤.៨៥៥លើក** | **៩១២.៥៥១នាក់** | **៤៥៥.៩៥០នាក់** |
| *(សម្គាល់៖ ចំនួននេះមិនគិតអ្នកដែលបានទទួលព័ត៌មានតាមរយៈការចែកខិត្តប័ណ្ណ បណ្តាញសង្គម ឬការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិកត្រូនិកផ្សេងទៀតឡើយ)* | | | | |

❖ **ការផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ និងភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**

| តារាងទិន្នន័យវេទិកាសាធារណៈ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | | | | | | |
|---|---|---|---|---|---|---|---|
| ល.រ | ក្រសួង ស្ថាប័ន រាជធានី ខេត្ត | ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | | វេទិកាសាធារណៈ | | |
| | | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្ត្រី | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
| ១ | គ.ជ.ប.ជ | ០២ | ៤១០ | | | | |
| រាជធានី ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | ៧៦ | ១១.០០៨ | ៥៨៨ | ១៨ | ៧២៤ | ៣៧៥ |
| ២ | កណ្តាល | | | | ៧០ | ៣.០៥៣ | ១.៣៦៤ |
| ៣ | បាត់ដំបង | ៩២៨ | ៥១.១២៦ | ២៨.២៤៤ | ៧០៦ | ២២.០៧២ | ១២.៦៧២ |
| ៤ | ពោធិ៍សាត់ | ៥០៦ | ៦០.៥៣០ | ៣៧.៧៥៦ | ៣២៥ | ១៣.០០៣ | ៦.៤៧៦ |
| ៥ | សៀមរាប | ១.១៥០ | ១០២.៨៥៥ | ៤៦.៧៧០ | ១.១២៦ | ៥១.១១២ | ៣០.៣៥៥ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៦ | កំពង់ឆ្នាំង | ៨៣៥ | ២៨.៩៦៦ | ១៤.៩៨៦ | ៤៩១ | ១៥.៩២៩ | ៨.១៧៨ |
| ៧ | កំពង់ចាម | ១.៧២៤ | ១០១.៤៦៣ | ៥០.២២៧ | ១ | ១៣៤ | ៧០ |
| ៨ | ព្រះសីហនុ | ១៥៧ | ៤.២៩៩ | ១.៩៤៣ | ៥៩ | ១.៦១៦ | ៧៤៧ |
| ៩ | ព្រះវិហារ | ១៦ | ៣.៣២៨ | ១.៥៤២ | ៣ | ៨៣៩ | ១៨៦ |
| ១០ | ស្វាយរៀង | ៤៤៦ | ២៦.៩៦៨ | ១៥.១១២ | ៥៥០ | ២២.២៤៩ | ១២.៧២៤ |
| ១១ | ប៉ៃលិន | ០៤ | ១.២៣៨ | ៦៣១ | ១១១ | ៤.០៩៣ | ១.៩៤៥ |
| ១២ | កោះកុង | ១៤៤១ | ២០.៦៨៤ | ៩.៤៥៤ | ៤៤៥ | ៦.៣០៧ | ២.៧៧៣ |
| ១៣ | តាកែវ | ៣១២ | ១២.៥១០ | ៦.២៦០ | | | |
| ១៤ | ក្រចេះ | ៦៤ | ២.១៦៦ | ១.២៧១ | | | |
| ១៥ | កែប | ៥៥ | ៩.០៤៨ | ៤.១៧៦ | ១១១ | ៤.៦៦៤ | ២.៥២៨ |
| ១៦ | ស្ទឹងត្រែង | ២០៥ | ១២.៧៣២ | ៧.២៤៥ | ១៧៨ | ៥.៧៧១ | ៣.២៤១ |
| ១៧ | ព្រៃវែង | ៩៤៣ | ៣១.៦៩២ | ១៧.៣១៤ | ៧៦២ | ២២.៨២៥ | ១២.១០៧ |
| ១៨ | ត្បូងឃ្មុំ | ៦៥ | ៨៥២ | ៤៨៩ | ៥១៧ | ១៦.១៤៦ | ៦.៧៧៦ |
| ១៩ | ឧត្តរមានជ័យ | ១៥៧ | ៧.៣៤១ | ៤.២៣៧ | ១៩ | ១៩.៦៨២ | ១.១១១ |
| សរុប | | ៩.០៨៦ | ៤៨៩.២១៦ | ២៤៨.២៤៥ | ៥.៤៩២ | ២១០.២១៩ | ១០៣.៦២៨ |
| សរុបរួម | | ១៤.៥៧៦លើក | | ៦៩៩.០២៥នាក់ | | ៣៥១.៨៧៣នាក់ | |

❖ ការបញ្ជ្រាបការយល់ដឹងតាមរយៈកម្មវិធីផ្សេងៗ

| ល.រ | ស្ថាប័ន រាជធានី ខេត្ត និងអង្គការដៃគូ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ខេត្តកណ្ដាល | ០៤ | ៦៥៧ | ២០១ |
| ២ | ខេត្តបាត់ដំបង | ២៣ | ៧៤២ | ២៩១ |
| ៣ | ខេត្តប៉ៃលិន | ០២ | ១២៣ | ៤២ |
| ៤ | ខេត្តសៀមរាប | ៧៧ | ៥១៨១ | ២៤១៣ |
| ៥ | ខេត្តកំពង់ឆ្នាំង | ០៦ | ២០១ | ៩៧ |
| ៦ | ខេត្តត្បូងឃ្មុំ | ០៣ | ៥៨៣ | ៣៣៦ |
| ៧ | ខេត្តឧត្តរមានជ័យ | ១៤៥ | ៦២២៧ | ៣៦៦៩ |
| ៨ | ខេត្តតាកែវ | ១៤ | ១៩៩៥០០ | ៩៦៩៥០ |
| ៩ | ខេត្តកែប | ០២ | ៦៥៧ | ៣២៥ |
| ១០ | អង្គការម្លប់តាប៉ាង(ព្រះសីហនុ) | ០១ | ១៥ | |
| ១១ | អង្គការជលជាតិជីវិត(ព្រះសីហនុ) | ០៣ | ២៤២ | ៤៥ |
| ១២ | អង្គការហាជហុក(ប៉ៃលិន) | ០១ | ៥៥ | ៣៣ |
| សរុប | | ២៧៩លើក | ២១៣.៥២៦នាក់ | ១០៤.០៧៧នាក់ |

## គ.២. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយមិនផ្ទាល់

❖ ការផលិត និងចែកផ្សាយសម្ភារផ្ដល់ព័ត៌មាន និងអប់រំ (IEC = Information Education Communication Materials)

| ល.រ | រាជធានី ខេត្ត | សកម្មភាព និងឧបករណ៍ផ្សព្វផ្សាយ | ចំនួនឧបករណ៍ | ចំនួនអ្នកទទួលបាន | ចំនួនស្ត្រី |
|---|---|---|---|---|---|
| ១ | សៀមរាប | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ១៨.៤២៨ប័ណ្ណ | | |
| ២ | ឧត្តរមានជ័យ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ៨៥០ប័ណ្ណ | | |
| ៣ | ព្រះវិហារ | -ខិត្តប័ណ្ណផ្សព្វផ្សាយ | ០៩ប័ណ្ណ | ៥០៣នាក់ | ១៤៦នាក់ |
| *សរុប* | | | *១៩.២៨៧ប័ណ្ណ* | *៥០៣នាក់* | *១៤៦នាក់* |

❖ ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

| ល.រ | ក្រសួង ស្ថាប័ន រាជធានី ខេត្ត | បណ្តាញផ្សព្វផ្សាយ | ចំនួនលើក | ចំនួនអ្នកទស្សនា/ស្តាប់/អាន/Views |
|---|---|---|---|---|
| ១ | សៀមរាប | -វិទ្យុជាតិ<br>-ខ្សែភាពយន្តវីដេអូអប់រំ | ១០៦<br>០៦ | ១.០៦០/ស្រី៧៥ |
| ២ | ត្បូងឃ្មុំ | -វិទ្យុជាតិ | ៣២ | |
| ៣ | ព្រៃវែង | -វិទ្យុជាតិ | ៥០ | |
| ៤ | ប៉ៃលិន | -វិទ្យុជាតិ | ៤៩៦ | |
| | *សរុប* | | *៦៩០លើក* | ១.០៦០/ស្រី៧៥ |

❖ ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ នៅតាមស្ថានីយវិទ្យុ និងទូរទស្សន៍

▪ ខេត្តសៀមរាប៖ តំណាងក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សស្រុកអង្គរជុំ បានចូលរួមជាវាគ្មិន តាមវិទ្យុជាតិខេត្ត ស្តីពីការគាំទ្រស្ត្រីឱ្យមានការងារធ្វើក្រោយវិលត្រឡប់មកពីក្រៅប្រទេស។

▪ ខេត្តកំពង់ចាម៖ តំណាងមន្ទីរការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមជាវាគ្មិន តាមវិទ្យុជាតិខេត្ត ស្តីពីដំណើរការទទួលនិងត្រៀមកន្លែងការងារសម្រាប់ពលករមកពីប្រទេសថៃ។

## ក.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ក.៣.១. ការទប់ស្កាត់ចំណាកស្រុកខុសច្បាប់

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ៖ កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានធ្វើការបង្ការទប់ស្កាត់ពលរដ្ឋខ្មែរ ដែលបម្រុងឆ្លងដែនខុសច្បាប់ទៅប្រទេសថៃចំនួន ០៤លើក មនុស្សចំនួន ២៩នាក់ ស្រី១៥នាក់ បានធ្វើកិច្ចសន្យាអប់រំ ណែនាំកុំឱ្យធ្វើចំណាកស្រុកដោយខុសច្បាប់ទៅក្រៅប្រទេសទៀត។

### ក.៣.២. ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈរូបភាពរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានសម្ភាសន៍ជនបរទេស ដែលមកដាក់ពាក្យសុំចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ តាមផ្លូវច្បាប់ ដូចមានក្នុងតារាងខាងក្រោម៖

| បរិយាយ | ចំនួនមនុស្ស | សញ្ជាតិ |
|---|---|---|
| ប្រុសបរទេសជាមួយស្រីខ្មែរ | ១៨៣នាក់ | កូរ៉េខាងត្បូង៣៤ស្រី៥, ចិន១២១, អាម៉េរិក១២, កាណាដា៦នាក់, បារាំង៤, អូស្ត្រាលី២, ម៉ាឡេស៊ី២, ហូឡង់២, អៀរឡង់១, អូទ្រីស១, ញូហ្ស៊ីឡែន១, ឡាវ១(ស្រី), នេប៉ាល់១ និងហ្វាំងឡង់១នាក់។ |
| ស្រីបរទេសជាមួយប្រុសខ្មែរ | ០៦នាក់ | |
| សរុប | ១៨៩នាក់ | ១៤ សញ្ជាតិ |

### ក.៣.៣. ការគ្រប់គ្រងស្ថិតិចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ និងជនបរទេស

❖ ការគ្រប់គ្រងស្ថិតិបច្ចុប្បន្នភាពចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ

• ទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុកទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទង រាជធានី ខេត្ត សរុបចំនួន ៥៦.២៦៩នាក់ ស្រី ២៣.៧០៨នាក់ អនីតិជន ៦៩៤នាក់ ស្រី ១៦៥នាក់ ក្នុងនោះ ៖

○ ស្របច្បាប់ចំនួន ៤៥.៩០៥នាក់ ស្រី ១៩.៨៣២នាក់ អនីតិជន ៤២៥នាក់ ស្រី ៨៧នាក់

○ មិនស្របច្បាប់ចំនួន ១០.១៧០នាក់ ស្រី ៣.៨០៦នាក់ អនីតិជន ២៦៥នាក់ ស្រី ៧៥នាក់

○ ជាប់ការទាក់ទងចំនួន ១៩៤នាក់ ស្រី ៧០នាក់ អនីតិជន ០៤នាក់ ស្រី ០៣នាក់។

• ទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់ពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ រាជធានី ខេត្ត សរុបចំនួន ៥១.៩៣៧នាក់ ស្រី ២៣.៣៦៥នាក់ អនីតិជន ៨៧៧នាក់ ស្រី ៣៤៤នាក់។

❖ ការទទួលពលរដ្ឋខ្មែរចំណាកស្រុកដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់

⚘ <u>ស្ថិតិពលរដ្ឋខ្មែរដែលត្រូវអាជ្ញាធរបរទេសបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែន(កម្ពុជា-ថៃ-វៀតណាម)</u>

▪ បានទទួលពលរដ្ឋខ្មែរដែលត្រូវអាជ្ញាធរថៃ និងអាជ្ញាធរវៀតណាមបញ្ជូនត្រឡប់មកវិញនៅតាមច្រកផ្សេងៗ សរុបចំនួន១៩លើក មនុស្សចំនួន ៣៧៦នាក់ ស្រី ១២៧នាក់ ក្នុងនោះខេត្តបាត់ដំបង ១៨លើក មនុស្ស ៣៧៥នាក់ ស្រី ១២៧នាក់ និងខេត្តស្វាយរៀង ០១លើក មនុស្ស ០១នាក់។

⚘ <u>ការទទួលពលករនៅតាមមណ្ឌលទទួលពលករ</u>

▪ មណ្ឌលទទួលពលករកំរៀង ខេត្តបាត់ដំបង បានទទួលពលករខ្មែរបញ្ជូនត្រលប់ពីអាជ្ញាធរថៃ សរុបចំនួន ៦៥៦នាក់ ក្នុងនោះស្ត្រី ២៤៨នាក់ និងជនមានពិការភាព ០២នាក់(ស្ត្រី ០១នាក់)។

### ក.៤. ការលើកកម្ពស់ជីវភាព

❖ ការផ្តល់ព័ត៌មានការងារ និងបង្កើនកម្មវិធីសិក្សា សម្រាប់អាជីពការងារ និងវិជ្ជាជីវៈ

▪ ខេត្តសៀមរាបៈ មជ្ឈមណ្ឌលការងារខេត្ត បានរៀបចំពិព័រណ៍ការងារចល័ត ០១លើក មានប្រជាពលរដ្ឋចូលរួមចំនួន ១១០នាក់ ស្រី ៥០នាក់។ បានប្រមូលព័ត៌មានជ្រើសរើសកម្លាំងពលកម្មពីគ្រប់ប្រភេទ ចំនួន ១០០កន្លែង។ បានទទួលអ្នកចុះឈ្មោះស្វែងរកការងារធ្វើចំនួន ៨៦នាក់ ស្រី ២៩នាក់ (អតីតពលករ ១៥នាក់ ស្រី ៦០នាក់)។ បានធ្វើការផ្គូផ្គងនិងបញ្ជូនអ្នកស្វែងរកការងារធ្វើទៅឱ្យនិយោជកចំនួន ១៣៤នាក់ ស្រី ៦០នាក់ (ពលករ ១៦នាក់ ស្រី ០៧នាក់)។ អ្នកទទួលបានការងារធ្វើចំនួន ៨៧នាក់ ស្រី ៣៨នាក់ (ពលករ ០៦នាក់ ស្រី ០២នាក់)។ បានផ្តល់ការប្រឹក្សាយោបល់អំពីអាជីពការងារ និងវិជ្ជាជីវៈទៅអ្នកស្វែងរកការងារធ្វើចំនួន ១៨៤នាក់ ស្រី ១០៩នាក់។ អ្នកទទួលបានកម្មសិក្សា ១១នាក់ ស្រី ០៤នាក់។ អ្នកទទួលបានព័ត៌មានទីផ្សារការងារតាមរយៈខិតប័ណ្ណ/កម្មវិធី ៧០០នាក់។

▪ ខេត្តព្រៃវែង មានពលករខ្មែរដែលវិលត្រលប់ពីប្រទេសថៃចំនួន ២១.៧២៥នាក់ ស្រី ៩.៣៨៦នាក់ អ្នកទទួលបានការងារធ្វើ ១៧.៥៥៩នាក់ ស្រី ៧.៥៥៨នាក់ ពុំទទួលបានការងារធ្វើ ៤.១៦៦នាក់ ស្រី ១.៨២៨នាក់។

▪ ខេត្តកំពង់ចាមៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយទីភ្នាក់ងារជាតិមុខរបរ និងការងារ ប.ស.ស និងវិទ្យាស្ថានពហុបច្ចេកទេសខេត្ត ចុះផ្សព្វផ្សាយ និងចុះឈ្មោះសិស្ស រៀនជំនាញបច្ចេកទេសវិជ្ជាជីវៈចំនួន ១៣៤នាក់ ស្រី ៧០នាក់។

### ក.៥. ការសិក្សាស្រាវជ្រាវ

▪ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជៈ ក្រុមការងារជំនាញ នៃគ.ជ.ប.ជ សហការជាមួយអង្គការ IJM និងលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តកោះកុង បានចុះធ្វើការសិក្សាស្រាវជ្រាវ និងប៉ាន់ប្រមាណអំពីប្រសិទ្ធភាព និងបញ្ហាប្រឈម ក្នុងការអនុវត្តបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប តាមរយៈធ្វើកិច្ចសម្ភាសន៍ជាមួយមន្ត្រីនគរបាល នៃអធិការដ្ឋាននគរបាលក្រុង/ស្រុកចំនួន៥ ក្នុងនោះមានៈ ក្រុងខេមរៈភូមិន្ទ ស្រុកមណ្ឌលសីមា ស្រុកថ្មបាំង ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល ដែលធ្លាប់បានចូលរៀនវគ្គបណ្តុះបណ្តាលកន្លងមក។

## ខ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ខ.១. ការងារអនុវត្តច្បាប់

❖ ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួ ២៧ករណី (ប្រៀបធៀបខែតុលា មានចំនួន ៣៨ករណី ថយចុះ ១១ករណី) ស្មើ២៨.៩៤% ៖

- ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត ចំនួន ៤១នាក់ ស្រី ០១នាក់ ជនសង្ស័យជាជនជាតិចិន ០៣នាក់។
- សង្គ្រោះជនរងគ្រោះចំនួន ១៥៤នាក់ ស្រី ៩៧នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំ ១៥នាក់ ស្រី១១នាក់ អាយុ១៥-១៧ឆ្នាំ ២៨នាក់ ស្រី២៧នាក់ និងអាយុ១៨ឆ្នាំឡើង ១១១នាក់(ស្រី) (បញ្ជូនទៅមន្ទីរសង្គមកិច្ច ៤៤នាក់ គ្រួសារ ១១០នាក់)។

ក្នុងនោះចែកជា៖

- <u>ករណីអំពើជួញដូរមនុស្ស</u>

បង្ក្រាបបាន ១៧/២០ករណី (ថយចុះ ០៣ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ២៩នាក់។ សង្គ្រោះជនរងគ្រោះចំនួន ១០១នាក់ ស្រី ៤៥នាក់ មានអាយុក្រោម១៥ឆ្នាំ ០៥នាក់ ស្រី០១នាក់ អាយុ១៥-១៧ឆ្នាំ ០៦នាក់ ស្រី០៥នាក់ និងអាយុ១៨ឆ្នាំឡើង ៩០នាក់ ស្រី៣៩នាក់ (បញ្ជូនទៅគ្រួសារ ១០១នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនរងគ្រោះ |
|---|---|---|---|
| ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០១ | ០២ | ០១ |
| ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ១៣ | ២២ | ៩០ |
| ការដឹកជញ្ជូនដោយមានគោលដៅ | ០១ | ០៣ | ០៤ |
| ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០១ | ០១ | ០៥ |
| ការទិញពេស្យាចាកុមារ | ០១ | ០១ | ០១ |
| *សរុប* | *១៧ករណី* | *២៩នាក់* | *១០១នាក់* |

- <u>ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ</u>

បង្ក្រាបបាន ១០/១៨ករណី (ថយចុះ ០៨ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១២នាក់ ស្រី០១នាក់ ជនជាតិចិន ០៣នាក់។ សង្គ្រោះជនរងគ្រោះចំនួន ៥៣នាក់ ស្រី៥២នាក់ មានអាយុក្រោម១៥ឆ្នាំ ១០នាក់(ស្រី) អាយុ១៥-១៧ឆ្នាំ ២២នាក់(ស្រី) និងអាយុ១៨ឆ្នាំឡើង ២១នាក់ ស្រី២០នាក់ (បញ្ជូនទៅមន្ទីរសង្គមកិច្ច ៤៤នាក់ គ្រួសារ ០៩នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ |
|---|---|---|---|---|
| ស្ថានទម្ងន់ទោស(ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង) | ០១ | ០៣ | ចិន៣ | ០១ |
| សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០៣ | ០៣ | | ៤៤ |
| រូបភាព និងសម្ភារៈអាសអាភាស | ០១ | ០១ | | ០១ |
| អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៤ | ០៤ | | ០៤ |
| អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១ | ០១ | | ០៣ |
| *សរុប* | *១០ករណី* | *១២នាក់* | *០៣នាក់* | *៥៣នាក់* |

## គ. កិច្ចការពារជនរងគ្រោះ

### គ.១. ការទទួល និងសម្ភាសពលករបញ្ជូនទាំងក្នុងប្រទេស និងត្រឡប់ពីក្រៅប្រទេស

▪ ក្រុមការងារការពារជនរងគ្រោះ នៃ គ.ជ.ប.ជ ដឹកនាំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ មន្ទីរសង្គមកិច្ចរាជធានី ខេត្ត និងអង្គការដៃគូ តាមរយៈនាយកដ្ឋានគាំពារជនរងគ្រោះនៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច បានទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សក្នុងប្រទេស និងក្រៅប្រទេស ចំនួន ២៨នាក់(ប្រុស០២នាក់ ស្រី២៣នាក់ កុមារ០១នាក់ កុមារី០២នាក់) និងបានការកំណត់អត្តសញ្ញាណពីមន្ត្រីនគរបាលយុត្តិធម៌ជំនាញទាំងអស់ ក្នុងនោះ៖

- ក្នុងប្រទេសចំនួន ០៥នាក់ (ប្រុស០២នាក់ ស្រី០២នាក់ កុមារ០១នាក់)
  - ខ្មែរកុមារា ០១នាក់(ករណីរំលោភបំពានផ្លូវភេទ)
  - បរទេស ០៤នាក់(ករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម) មានជនជាតិថៃ ០២នាក់(ប្រុស០១នាក់ ស្រី០១នាក់) ចិន០១នាក់(ស្រី) និងកូរ៉េខាងត្បូង ០១នាក់(ប្រុស)។
- ក្រៅប្រទេសចំនួន ២៣នាក់ (ស្រី២១នាក់ កុមារី០២នាក់)
  - ប្រទេសចិន ២២នាក់(ស្រី២១នាក់ កុមារី០១នាក់) ករណីរៀបអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ
  - ប្រទេសមីយ៉ាន់ម៉ា ០១នាក់(កុមារី) ករណីអាជីវកម្មផ្លូវភេទ។

### គ.២. ការផ្តល់សេវា

មន្ទីរកិច្ចការនារីខេត្តព្រះសីហនុ ដោយទទួលកិច្ចសហការពីស្នងការដ្ឋាននគរបាលខេត្ត មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត និងអង្គការម្លប់តាប៉ាង បានផ្តល់សេវាប្រឹក្សាយោបល់ផ្នែកច្បាប់ ផ្លូវចិត្តដល់កុមារីរងគ្រោះដោយអំពើជួញដូរមនុស្ស និងធ្វើអាជីកម្មផ្លូវភេទចំនួន ០៣នាក់ ព្រមទាំងឧបត្ថម្ភថវិកាចំនួន ១០០,០០០រៀល ក្នុងមួយនាក់ និងសម្ភារៈប្រើប្រាស់ របស់អង្គការ UNFPA។

### គ.៣. ការស្តារនីតិសម្បទា

ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស បានបញ្ជូនទៅស្តារនីតិសម្បទា នៅមជ្ឈមណ្ឌលរបស់អង្គការចំនួន ២៨នាក់(ស្រី២៣ កុមារ០១ កុមារី០២) ក្នុងនោះ៖ អង្គតេនះអ៊ីនធើណេសិនណល០៦នាក់(ស្រី) អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ១៦នាក់(ស្រី១៥ កុមារី០១) អង្គការការីតាសកម្ពុជា០៥នាក់(ស្រី០២ កុមារី០១) និងអង្គការដើម្បីភាពញញឹមនៃកុមារ ០១នាក់កុមារា។

### គ.៤. ការធ្វើសមាហរណកម្មជនរងគ្រោះ

បានសមាហរណកម្មជនរងគ្រោះត្រឡប់ទៅសហគមន៍វិញចំនួន ១៣នាក់(ស្រី០៨នាក់ កុមារី០៥នាក់)។

### គ.៥. ការធ្វើមាតុភូមិនិវត្តន៍

ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទ ដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសដើមវិញ មានជនជាតិថៃ ០១នាក់(ស្រី)។

### គ.៦. ការតាមដានជនរងគ្រោះ

បានតាមដានជនរងគ្រោះចំនួន ២២៧នាក់(ប្រុស០៤នាក់ ស្រី៨០នាក់ កុមារ១៨នាក់ កុមារី១២៥នាក់)។

### គ.៧. ការបិទករណី

បានបិទករណី នៃការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ២៥នាក់(ស្រី១៩នាក់ កុមារី០៦នាក់)។

## ឃ. ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចសហប្រតិបត្តិការ

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
  - បានប្រកាសដាក់ឱ្យប្រើប្រាស់ គោលការណ៍ណែនាំ ស្តីពីបទដ្ឋានអប្បបរមា ដើម្បីផ្តល់សេវាសមាហរណកម្ម និងសេវាបញ្ជូន សម្រាប់មណ្ឌលទទួលពលករកំរៀង ខេត្តបាត់ដំបង។
  - បានចុះអនុស្សរណៈនៃការយោគយល់ ជាមួយ ក្រុមហ៊ុន សាស្ត្រា ឯ.ក កិច្ចសហប្រតិបត្តិការ និងការលើកកម្ពស់ប្រសិទ្ធភាពការងារផ្សព្វផ្សាយ អប់រំ អំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

# III. ការលើកកម្ពស់សមត្ថភាព និងការដឹកនាំសម្របសម្រួល

## ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

### ក.១. ការបណ្តុះបណ្តាល

❖ ការបណ្តុះបណ្តាលក្នុងប្រទេស

| ល.រ | សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | ចំនួនរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ នៃ គ.ជ.ប.ជ ដោយមានការសម្របសម្រួលពីរដ្ឋបាលខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការបញ្ជ្រាបការយល់ដឹងភាពជាអ្នកដឹកនាំ ដើម្បីការផ្លាស់ប្តូរឥរិយាបថ ដែលនាំឱ្យការបង្ការទប់ស្កាត់ អំពើជួញដូរមនុស្ស ទទួលបានប្រសិទ្ធភាពខ្ពស់ និងពិនិត្យមើលបទដ្ឋានអប្បរមា ក្នុងការផ្តល់សេវាសមាហរណកម្ម និងសេវាបញ្ជូនសម្រាប់មណ្ឌលទទួលពលករ នៅមជ្ឈមណ្ឌលសំចតនិងស្តារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត និងមណ្ឌលទទួលពលករកំរៀង។ | ០២ | ៨៦ | ១៤ |
| ២ | នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយនាយកដ្ឋានកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល បើកវគ្គបំប៉នជំនាញ ស្តីពីតួនាទីភារកិច្ចរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាល នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប និងស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ នៅខេត្តសៀមរាប។ | ០១ | ១៨០ | ៣៤ |
| ៣ | ខេត្តសៀមរាប មានការគាំទ្រពីអង្គការ CWCC រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ពិធីសារប៉ាឡឺម៉ូ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ | ០១ | ៣០ | ១៧ |
| | *សរុប* | *០៤វគ្គ* | *២៩៦នាក់* | *៦៥នាក់* |

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. កិច្ចប្រជុំ

❖ ការរៀបចំកិច្ចប្រជុំនៅក្នុងប្រទេស

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំកិច្ចប្រជុំចំនួន ០២លើក អ្នកចូលរួមចំនួន ៥០នាក់ ស្រី ២២នាក់៖ -កិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួង ការធ្វើបច្ចុប្បន្នភាពលើកគោលការណែនាំស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្របលើកទី៦។ -កិច្ចប្រជុំវគ្គបណ្តុះបណ្តាល គ្រូបង្គោលលើសៀវភៅណែនាំ ស្តីពីនីតិប្រតិបត្តិកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

▪ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានរៀបចំកិច្ចប្រជុំចំនួន ០៨លើក មានអ្នកចូលរួមចំនួន ១០៤នាក់ ស្រី ៤៤នាក់ ក្នុងនោះ៖

- កិច្ចប្រជុំអន្តរក្រសួងត្រៀមរៀបចំ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០២៥ ចំនួន ០១លើក អ្នកចូលរួមចំនួន ៥៩នាក់ ស្រី ២៤នាក់ នៅទីស្តីការក្រសួងមហាផ្ទៃ

- កិច្ចប្រជុំ ស្តីពីការកែសម្រួលខ្លឹមសារ ពិភាក្សាផ្តល់យោបល់ពីអនុស្សរណៈនៃការយោគយល់ រវាងអង្គការពារកុមារនៃអង្គការមូលនិធិកុមារជាតិ (CPU) និងក្រសួងមហាផ្ទៃសម្រាប់រយៈពេល៦ឆ្នាំ ចំនួន ០១លើក អ្នកចូលរួមចំនួន ២១នាក់ ស្រី ០៣នាក់ នៅសាលប្រជុំ គ.ជ.ប.ជ

- កិច្ចប្រជុំជាមួយអង្គការ ម៉ារីស៊ី អង្គការ IJM អង្គការ CPU អង្គការ CWCC និងអង្គការHAGA ត្រៀមរៀបចំ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០២៥ ចំនួន ០១លើក អ្នកចូលរួមចំនួន ២០នាក់ ស្រី ០៨នាក់ នៅទីស្តីការក្រសួងមហាផ្ទៃ

- កិច្ចប្រជុំផ្ទៃក្នុង ត្រៀមរៀបចំ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០២៥ ចំនួន ០៥លើក អ្នកចូលរួមចំនួន ៤២នាក់ ស្រី ០៩នាក់ នៅសាលប្រជុំ គ.ជ.ប.ជ។

▪ **លេខាធិការដ្ឋាន ខេត្តសៀមរាប និងខេត្តព្រះវិហារ** បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំខែវិច្ឆិកា ឆ្នាំ២០២៥ ចំនួន ០២លើក អ្នកចូលរួមចំនួន ៨៩នាក់ ស្រី ៤៥នាក់ ក្នុងនោះមានខេត្ត៖ -សៀមរាប ០១លើក អ្នកចូលរួម ៧៤នាក់ ស្រី ៤០នាក់។ -ព្រះវិហារ ០១លើក អ្នកចូលរួម ១៥នាក់ ស្រី ០៥នាក់។

❖ **ការចូលរួមកិច្ចប្រជុំនៅក្រៅប្រទេស**

▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំប្រតិភូក្រុមការងារខមមីតកម្ពុជា ចូលរួមកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំជាន់ខ្ពស់លើកទី៦ (IMM6) បន្ទាប់ពីក្រុមការងារបច្ចេកទេសអន្តរក្រសួង (RTF) នៅទីក្រុងហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។ ជាលទ្ធផលគឺបានអនុម័ត ផែនការជំហានទី៥ (SPA V) ២០២៥-២០៣៥ អនុម័តសេចក្តីថ្លែងការណ៍រួម និងទិសដៅ ក្នុងការធ្វើឱ្យសកម្មភាពប្រឆាំងការជួញដូរមនុស្ស មាននិរន្តរភាព តំណាងប្រទេសទាំង៦ មានរដ្ឋមន្ត្រីមីយ៉ាន់ម៉ា អនុរដ្ឋមន្ត្រីចិន អនុរដ្ឋមន្ត្រីឡាវ អនុរដ្ឋលេខាធិការថៃ រដ្ឋលេខាធិការកម្ពុជា និងអនុរដ្ឋមន្ត្រីវៀតណាម។

▪ លោកស្រី ប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ បានចូលរួមកិច្ចសន្ទនាសិទ្ធិមនុស្សអាស៊ានលើកទី៧ និងពិធីប្រារព្ធខួបសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី។

### ខ.២. ជំនួបពិភាក្សាការងារ

▪ **ខេត្តសៀមរាប៖** តំណាងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានទទួលជួបពិភាក្សាការងារជាមួយអង្គការ ILO ស្តីពីកិច្ចគាំពារផ្នែកច្បាប់ដល់ពលករលើទូកនេសាទ ចំនួន ០១លើក តាមរយៈប្រព័ន្ធ Zoom។

### គ. ការងារសម្របសម្រួល

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំដឹកនាំសម្របសម្រួល និងចូលរួមកិច្ចប្រជុំនានា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សរុបចំនួន ១៨លើក។ (**ឧបសម្ព័ន្ធ**)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែងរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការកំណត់យកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអាទិភាពមួយក្នុងចំណោមអាទិភាពនៃផែនការដែលត្រូវយកចិត្តទុកដាក់ គឺជាថាមពលជំរុញចិត្តឱ្យគ្រប់សមាសភាពក្នុងសង្គមទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ និងដៃគូ ជាតិ និងអន្តរជាតិ ឱ្យរឹតតែប្រឹងប្រែងទ្វេឡើងទៀត

- ច្បាប់ គោលនយោបាយ វិធានការ អនុសាសន៍របស់ប្រមុខដឹកនាំទាំងក្នុងនីតិកាលចាស់ និងថ្មី នៅតែមានគុណតម្លៃសម្រាប់ការអនុវត្ត ជាមូលដ្ឋានបង្អែក និងជាប្រទីបបំភ្លឺផ្លូវសម្រាប់ការកំណត់ការងារជាយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្ស
- សន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត នៅតែមានតម្លៃជាកិច្ចសហប្រតិបត្តិការទូលំទូលាយលើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងអំពើពាក់ព័ន្ធដទៃទៀត
- រចនាសម្ព័ន្ធនៃយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាកម្លាំងស្នូលក្នុងការអនុវត្តការងារ តាមក្រសួងស្ថាប័នមន្ទីរ អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន បានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធទាំងឡាយក្នុងសង្គមកម្ពុជា
- ការចូលរួមឧបត្ថម្ភគាំទ្រពីអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ វិស័យឯកជន និងកិច្ចសហការក្នុងការបំពេញភារកិច្ចតាមក្រសួងស្ថាប័ន មន្ទីរ អង្គភាព គឺជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុបសម្រាប់រួមគ្នាធ្វើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដ៏មានសក្តានុពល។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម មួយចំនួនដូចជា៖

- ទាមទារការយកចិត្តទុកដាក់បន្ថែមទៀត លើការចាត់តាំងមន្ត្រីទទួលបន្ទុកឱ្យបានជាក់លាក់ លើការងាររបាយការណ៍ ការងារផែនការ ការងារសម្របសម្របសម្រួល ការងាររដ្ឋបាលហិរញ្ញវត្ថុ សម្រាប់អនុវត្តយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមក្រសួងស្ថាប័ន មន្ទីរអង្គភាពនីមួយៗ ចៀសវាងការផ្លាស់ប្តូរញឹកញាប់ ឬគ្មានអ្នកទទួលខុសត្រូវច្បាស់លាស់
- ត្រូវការពិភាក្សាបន្ថែម លើការកំណត់ឯកតាសម្រាប់ទិន្នន័យនៃរបាយការណ៍ ឧទាហរណ៍ ពាក្យថា ជនរងគ្រោះ ជនងាយរងគ្រោះ ជនសង្ស័យថារងគ្រោះ...ដែលធ្វើឱ្យការបូកសរុបទាំងបរិមាណ និងគុណភាព មិនទាន់ស៊ីចង្វាក់គ្នា
- ត្រូវការរៀបចំកែលម្អ រចនាសម្ព័ន្ធ តួនាទី ភារកិច្ច របស់គណៈកម្មាធិការជាតិ គ្រប់លំដាប់ថ្នាក់ ដោយយកចិត្តទុកដាក់បន្ថែមលើការជួញដូរ ដែលពាក់ព័ន្ធនឹងអំពើឆបោកតាមអនឡាញ ដែលមានភាពស្មុគស្មាញ ដើម្បីឱ្យការធ្វើសកម្មភាព និងទិន្នន័យមានសង្គតិភាព និងកាន់តែជាក់លាក់
- ជនល្មើសមានកលល្បិចខ្ពស់ ក្នុងការធ្វើសកម្មភាពខុសច្បាប់ ជាប្រព័ន្ធ និងអូសទាញមនុស្សឱ្យរងគ្រោះជាបន្តបន្ទាប់ ជាពិសេស នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- ខ្វះការផ្សព្វផ្សាយអំពីលទ្ធផលការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលឆ្លើយតបទៅនឹងការចោទប្រកាន់ ជាពិសេស ករណីជនបរទេស
- ខ្វះវិធីសាស្ត្រសមស្រប និងសង្គតិភាពនៃសារអប់រំ ផ្សព្វផ្សាយ និងគម្រោងសកម្មភាពនានា ដែលអាចធ្វើឱ្យការបង្ការទប់ស្កាត់ អំពើជួញដូរ គ្រប់ទំរង់ ទទួលបានប្រសិទ្ធភាព ដែលអាចឱ្យមនុស្សផ្លាស់ប្តូរឥរិយាបថ មិនធ្វើទេសន្តរប្រវេសន៍ ដោយប្រថុតយប្រថាន និងគ្រោះថ្នាក់។

## គ. សេចក្តីសន្និដ្ឋាន និងសំណូមពរ

បទល្មើសជួញដូរមនុស្ស និងបទល្មើសឆបោកតាមអនឡាញ មានភាពប្រទាក់ក្រឡាគ្នា កាន់តែស្មុគស្មាញ និងរីកសាយឆាប់រហ័ស អាស្រ័យដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបជាមធ្យោបាយសម្រាប់បង្កើនប្រសិទ្ធភាពបទល្មើសឱ្យកាន់តែមានកម្រិតខ្ពស់ និងអាចខ្ពស់ជាងបច្ចេកទេសដែលសមត្ថកិច្ចប្រើប្រាស់បច្ចុប្បន្ន។ ជនល្មើស និងជនរងគ្រោះ អាចជាមនុស្សតែមួយ ដែលធ្វើឱ្យការកំណត់អត្តសញ្ញាណ មានការលំបាក និងប្រើពេលយូរ។

ករណីឆបោកតាមអនឡាញ មានពាក់ព័ន្ធនឹងសកម្មភាពជួញដូរមនុស្ស និងបទល្មើសទ្រព្យហិរញ្ញវត្ថុផ្សេងទៀត ជាច្រើនទម្រង់ មានជាអាទិ៍ អំពើឆបោក អំពើចាប់ជំរិត ការបង្ខំឱ្យធ្វើការងារខុសច្បាប់ គំនុំសងសឹក ទំនាស់ការងារ អំពើហិង្សា ឃាតកម្មការងារដោយបង្ខំ ខុសច្បាប់ការងារ ខុសច្បាប់អន្តោប្រវេសន៍ ការបន្លំជាជនរងគ្រោះដើម្បីគេច ពីសំណាញ់ច្បាប់ ជាដើម។

យុទ្ធសាស្ត្របង្ការទប់ស្កាត់ នៅតែជាអាទិភាព ដែលត្រូវយកចិត្តទុកដាក់ខ្ពស់ និងចាំបាច់ត្រូវមានការចូលរួម ពីបណ្តាក្រសួង ស្ថាប័ន អង្គភាព ពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបញ្ចៀសភាពរងគ្រោះ និង កាត់បន្ថយ សក្តានុពលនៃបទល្មើស។ ការបង្កើនការបង្ការទប់ស្កាត់ នឹងអាចការពារ មនុស្សគ្រប់វ័យ តាំងពីដំណាក់ កាលដំបូង ដោយមិនរង់ចាំបទល្មើសកើតឡើង និងមានអ្នករងគ្រោះ ទើបធ្វើការស៊ើបអង្កេត ស្រាវជ្រាវ បង្ក្រាប សង្គ្រោះ ផ្តន្ទាទោស ផ្តល់កិច្ចការពារ... ដែលជាខាតបង់ដ៏ច្រើនលើសលុប ទាំងធនធានមនុស្ស ធនធានថវិកា កេរ្តិ៍ឈ្មោះ កិត្តិយស សេចក្តីថ្លៃថ្នូរ សុខភាពរាងកាយ ផ្លូវចិត្ត រហូតដល់អាយុជីវិត ពេលវេលា ទំនាក់ទំនងសង្គម និង ជាឧបសគ្គ ក្នុងការអភិវឌ្ឍន៍គ្រប់វិស័យ។

ការពង្រឹងស្ថាប័ន សមត្ថភាពជំនាញ និងឥរិយាបថមន្ត្រីគ្រប់ឋានានុក្រមក្នុងការទទួលខុសត្រូវ តាមវិស័យ ជំនាញនីមួយៗ ក៏ដូចជាការកសាងទំនុកចិត្តរវាងគ្នាដើម្បីបង្កើតជាបណ្តាញសមត្ថកិច្ចដ៏រឹងមាំការពារសុវត្ថិភាព ប្រជាពលរដ្ឋ និងការពិនិត្យឡើងវិញ នូវនីតិវិធីច្បាប់ ក៏ដូចជាកិច្ចសហការរវាងវិស័យពាក់ព័ន្ធ ប្រទេសពាក់ព័ន្ធ ក្នុង តំបន់ និងជាអន្តរជាតិ នៅតែមានភាពចាំបាច់ មិនអាចខ្វះបាន ក្នុងការកាត់បន្ថយ ឈានទៅលុបបំបាត់រាល់ទម្រង់ នៃអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធ។

ជាសំណូមពរ ចំពោះ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ក្នុងយន្តការនៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស៖

- គប្បីចាត់តាំងមន្ត្រីឱ្យទទួលខុសត្រូវ បំពេញតាមរចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់ថ្នាក់ឱ្យបានច្បាស់លាស់ ដើម្បីទទួលបន្ទុកការងារទំនាក់ទំនង សម្របសម្រួល ការងាររបាយការណ៍ ការងារផែនការ និងការងាររដ្ឋបាល ហិរញ្ញវត្ថុ និងទទួលបានការបណ្តុះបណ្តាលអំពីតួនាទី ភារកិច្ចដែល ឆ្លើយតបទៅនឹងការងារប្រឆាំងអំពើ ជួញដូរមនុស្ស
- ពង្រឹងរបបប្រជុំ ឱ្យបានទៀងទាត់ ដើម្បីបូកសរុប និងតាមដានការងារលទ្ធផលការងារ ដែលអនុវត្ត ផ្អែក លើផែនការ និងយុទ្ធសាស្ត្រដែលបានកំណត់ ពង្រឹងប្រសិទ្ធភាពឬកែលម្អចំណុចខ្វះខាត ក្នុងក្រុមការងារ អន្តរក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងគណៈកម្មាធិការ និងលេខាធិការដ្ឋានខេត្ត ក្រុង ស្រុក ខណ្ឌ (គ.ខ/ រ.ប.ជ) ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស និងផ្ញើមកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឱ្យបានទាន់ពេលវេលា។

## V. ទិសដៅអនុវត្តបន្ត

ដើម្បីពង្រឹងបន្ថែមនូវកិច្ចខិតខំប្រឹងប្រែង ដែលនៅតែប្រឈមនឹងការវាយតម្លៃ មិនទាន់បានល្អប្រសើរនៅ ឡើយ និងដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាព តាមយុទ្ធសាស្ត្រទាំងបួនដែលបានកំណត់ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏ដូចជាដើម្បីពង្រឹងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មា ធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សូមដាក់ចេញនូវទិសដៅដើម្បីអនុវត្តបន្ត ដូចខាងក្រោម៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយជាមួយបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន បន្តអនុវត្តវិធានការបង្ការទប់ស្កាត់ ដែលឈានដល់ការផ្លាស់ប្តូរឥរិយាបថ តាមរយៈការជួបប្រជុំ ពិភាក្សាជាក្រុមនៃវិស័យពាក់ព័ន្ធ បង្កើតសកម្មភាពរួមគ្នា ដែលបង្កើនភាពជឿជាក់ពីប្រជាពលរដ្ឋ ជាពិសេស ក្រុមជនទេសន្តប្រវេសន៍ដែលវិលត្រឡប់ពីប្រទេសថៃ និងក្រុមប្រជាជន ដែលភៀសសឹក និងបែងចែកភារកិច្ច ពង្រាយបណ្តាញ ជាកម្លាំង ឆ្ពោះទៅកាន់តំបន់គោលដៅជាអាទិភាព

២. ត្រៀមប្រកាស ឯកសារ ស្តីពីការតាមដាន វាយតម្លៃ និងសិក្សា (MEL) ដើម្បីអនុវត្តក្នុងការវាយតម្លៃផែនការ យុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

៣. ត្រៀមរៀបចំកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល ដើម្បីពង្រឹងកិច្ចសហការចែករំលែក ការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេស ពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត

៥. ចូលរួមកិច្ចប្រជុំបច្ចេកទេស និងកិច្ចប្រជុំកំពូល ដើម្បីពង្រឹងកិច្ចសហការ ក្នុងមហាអនុតំបន់មេគង្គ និងកិច្ចប្រជុំផ្សេងៗ ថ្នាក់តំបន់ និងជាអន្តរជាតិ

៦. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព ការបញ្ជ្រាបតាមវេទិកាសាធារណៈ នៃគោលនយោបាយភូមិ ឃុំសង្កាត់មានសុវត្ថិភាព កម្មវិធីបុណ្យជាតិ ការរៀបចំយុទ្ធនាការទិវាជាតិ ១២ធ្នូ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស... និងប្រើគ្រប់លទ្ធភាព ធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាង ទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋ ជាពិសេស ស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ

៧. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ នៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជាក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដាន ការអនុវត្ត

៨. ជំរុញតាមដានត្រួតពិនិត្យ ក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ

៩. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេស ការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ

១០.ជំរុញការអនុវត្តគោលការណ៍ណែនាំ ស្តីពីការកំណត់អត្តសញ្ញាណរកភាពរងគ្រោះ ដើម្បីផ្តល់សេវាសមស្របដែលជានិយាមមិនអាចខ្វះបាន ក្នុងការអនុវត្ត

១១.ចូលរួមដោះស្រាយបញ្ហានៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្នមុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬនៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម

១២.បន្តដោះស្រាយ ឱកាសការងារ មុខរបរ និងការបង្កើតកម្មវិធីរកប្រាក់ចំណូលតាមវិធីសាស្ត្រជំនាញ នៃវិស័យពាក់ព័ន្ធដល់ប្រជាពលរដ្ឋ ជាពិសេស ជនទេសន្តរប្រវេសន៍វិលត្រឡប់ និងគ្រួសារជនភៀសសឹក៕

ថ្ងៃ..................ខែ.............. ឆ្នាំ ម្សាញ់ សប្តស័ក ព.ស ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ..............ឆ្នាំ២០២...

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ_ប៊ុនអេង**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ
## ការដឹកនាំ សម្របសម្រួល

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
  - ពិធីផ្សព្វផ្សាយអនុក្រឹត្យ ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងទង់នគរបាលជាតិកម្ពុជា។ កិច្ចពិភាក្សាលើការងារកំណែទម្រង់ តម្រង់ទិស និងពង្រឹងការងារវិស័យសន្តិសុខ នៃកងកម្លាំងនគរបាលជាតិ។ និងកិច្ចប្រជុំ ដោះស្រាយបណ្តឹងអន្តរាគមន៍ជនរងគ្រោះជាជនបរទេស ករណីឆបោកអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ។
  - ជាអធិបតី ក្នុងកិច្ចប្រជុំ បូកសរុបលទ្ធផលនៃការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ប្រចាំឆមាសឆ្នាំ២០២៥ និងទិសដៅអនុវត្តបន្ត នៅសាលប្រជុំសាលាខេត្តកំពង់ឆ្នាំង
  - ដឹកនាំកិច្ចពិភាក្សាលើកទី២ ត្រៀមរៀបចំកិច្ចប្រជុំក្រុមការងារ ខមមីតថ្នាក់តំបន់ Regional Taskforce Meeting (RTF) និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី Inter-Ministerial Meeting (IMM) លើកទី៦ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៧-២១ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅទីក្រុងហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្រោមមូលបទ "ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ក្នុងយុគសម័យឌីជីថល" តាមរយៈប្រព័ន្ធ Zoom Meeting ចេញពីសាលប្រជុំ គ.ជ.ប.ជ
  - ដឹកនាំប្រតិភូនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នាំយកនូវអំណោយជាសម្ភារៈប្រើប្រាស់ និងគ្រឿងឧបភោគបរិភោគ ចំនួន ២៥០កញ្ចប់ ជូនដល់គ្រួសារជនភៀសសឹក មកពីភូមិព្រៃចាន់ និងភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដែលទើបនឹងជម្លៀសសារជាថ្មី ដោយសារតែការបាញ់ប្រហារពីទាហ៊ានសៀម។
- លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ ប៉ុណ្ណ **សំខាន** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
  - កិច្ចប្រជុំពិភាក្សាលើការរៀបចំសេចក្តីព្រាង ប្រតិបត្តិសម្រាប់អនុវត្តអនុស្សរណៈនៃការយោគយល់ ស្តីពីកិច្ចសហប្រតិបត្តិការកិច្ចការពារកុមារ ក្នុងបរិបទទេសន្តប្រវេសន៍ រៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឧបត្ថម្ភគាំទ្រដោយអង្គការ UNICEF និងសហគមន៍ EU នៅសណ្ឋាគារ អេរ៉ា ភ្នំពេញ
  - ប្រកាសដាក់ឱ្យប្រើប្រាស់ គោលការណ៍ណែនាំ ស្តីពីបទដ្ឋានអប្បបរមា ដើម្បីផ្តល់សេវាសមាហរណកម្ម និងសេវាបញ្ជូនសម្រាប់មណ្ឌលទទួលពលករកំរៀង ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅខេត្តបាត់ដំបង
  - កិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់តំបន់ (RPSC) មានការចូលរួមពីសមាជិក (RPSC) ទាំង៧ប្រទេស មានការសម្របសម្រួលនិងឧបត្ថម្ភគាំទ្រពីកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស(ASEAN-ACT) តាមរយៈកម្មវិធី Zoom ពីការិយាល័យប្រទេសកម្ពុជា នៃកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) រាជធានីភ្នំពេញ។
- លេខាធិការដ្ឋាន គ.ជ.ប.ជ
  - លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ (២៣ច្បាប់) លិខិតចូល (១៨ច្បាប់)
  - លិខិតរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ(៣៣ច្បាប់)លិខិតចូល(១៥ច្បាប់)
- ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់
  - បានរៀបចំពិធីផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង ស្តីពីការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស និងចំណាកស្រុកដោយគ្មានសុវត្ថិភាព ជម្រើសមុខរបរ និងការងារ ដល់សិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅវិទ្យាល័យ ជា ស៊ីម ឈូកវ៉ា
  - បានរៀបចំពិធីផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង ស្តីពីការបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្ស ក្នុងវិស័យព័ត៌មាន ដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃក្រសួងព័ត៌មាន អ្នកសារព័ត៌មានជាតិ អ្នកបង្កើតមាតិកាតាមបណ្តាញព័ត៌មានសង្គមអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំទីស្តីការក្រសួងព័ត៌មាន។

- ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍
  - ចូលរួមកិច្ចប្រជុំផ្ទៃក្នុង ស្តីពីការរៀបចំការងារផ្នែកសន្តិសុខ សណ្តាប់ធ្នាប់ សុខាភិបាល ផ្គត់ផ្គង់ និងដឹកជញ្ជូន ត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០២៥ ក្រោមអធិបតីភាព លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។
- ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ
  - ចូលរួមសិក្ខាសាលា គំរូសិក្សា(Typology) ប្រចាំឆ្នាំ២០២៥ របស់ប្រទេសអាស៊ីប៉ាស៊ីហ្វិក ស្តីពីការសម្អាតប្រាក់ (APG) នៅសាលប្រជុំធនាគារជាតិកម្ពុជា
  - ចូលរួមជំនួបសំណេះសំណាល និងសម្ភាសជាមួយសិក្ខាកាម ដើម្បីឆ្លុះបញ្ចាំងពីចំណេះដឹង ក្រោយពីការបណ្តុះបណ្តាលកន្លងមក ស្តីពីបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប កិច្ចសហការ និងឧបត្ថម្ភពីអង្គការ បេសកកម្មយុត្តិធម៌អន្តរជាតិ នៅខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ
  - ចូលរួមសិក្ខាសាលា ស្តីពីការផ្ទៀងផ្ទាត់របាយការណ៍ សិក្សាស្រាវជ្រាវ ផលប៉ះពាល់លើពលករចំណាកស្រុកដែលត្រឡប់មកវិញ អំឡុងពេលមានជម្លោះព្រំដែន នៅសណ្ឋាគារសាន់វេ ភ្នំពេញ។
- ក្រុមជំនួយកិច្ចការអនុវត្តច្បាប់
  - ចូលរួមកិច្ចចរចា ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ឆ្នាំ២០២៥ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាឡឺម៉ង់ រយៈពេល២ថ្ងៃ នៅវិមានរដ្ឋាភិបាល។
- ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ
  - រៀបចំកិច្ចប្រជុំជាមួយក្រុមជំនួយកិច្ចការយុត្តិធម៌ ស្តីពីការរៀបផែនការ ដើម្បីរៀបចំថវិកាសម្រាប់ឆ្នាំ២០២៦
  - ចូលរួមសិក្ខាសាលា«2025 KACPE International Pacific Policy Symposium: Advancing Together: Korea-ASEAN Strategic Alliance Toward ASEAN Vision 2045» ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **លី ធុជ** ទេសរដ្ឋមន្ត្រីទទួលបន្ទុក បេសកកម្មពិសេស និងជាប្រធានគណៈកម្មាធិការជាតិអេស្កាប់ នៅសណ្ឋាគារ Shangri-La Phnom Penh។